# កតិកាសញ្ញាពិភពលោក
# ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់
# ផែនការអនុវត្តជាតិសម្រាប់កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍
# (ពង្រាង)
# ព្រះរាជាណាចក្រកម្ពុជា

## សេចក្តីសង្ខេប

កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ (Resolution A/RES/73/195) ។ កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍នេះ បង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំចំនួន ១០ ដែលជម្រុញអោយមានការបង្កើតវិធីសាស្ត្ររួមមួយសម្រាប់ទេសន្តរប្រវេសន៍ ហើយទាមទារឱ្យមានការចូលរួមពីគ្រប់កម្រិតទាំងអស់របស់ស្ថាប័នរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ សហជីព វិស័យឯកជន សង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ។ គោលការណ៍ណែនាំនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈគោលបំណងទាំង ២៣ របស់កតិកាសញ្ញា ដែលត្រូវបានលើកទឹកចិត្តឱ្យរដ្ឋហត្ថលេខីអនុវត្តកតិកាសញ្ញានេះអោយបានជាប់លាប់តាមរយៈការបង្កើតផែនការជាតិសម្រាប់ប្រទេសនីមួយៗ (កថាខណ្ឌ 53) ។

យោងលើកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ វេទិកាវាយតំលៃទេសន្តរប្រវេសន៍អន្តរជាតិ (IMRF) នឹងដើរតួនាទីជាវេទិកាអន្តររដ្ឋាភិបាលសកលចំបងមួយ ក្នុងការពិភាក្សា ចែករំលែក និងវាយតម្លៃការអនុវត្តគោលបំណងទាំង ២៣។ វេទិកាវាយតំលៃទេសន្តរប្រវេសន៍អន្តរជាតិនឹងប្រព្រឹត្តទៅ នូវរៀងរាល់បួនឆ្នាំម្តង ហើយជាលទ្ធផល នឹងមានសេចក្តីប្រកាសអន្តររដ្ឋាភិបាល ស្តីពីវឌ្ឍនភាពនៅក្នុងដំណាក់កាលនីមួយៗ។

តាមរយៈការអនុម័តទទួលអនុវត្ត GCM រាជរដ្ឋាភិបាលកម្ពុជាមានការតាំងចិត្តខ្ពស់ក្នុងការបំពេញឱ្យបាននូវគោលបំណង និងគ្រោងការដែលបានកំណត់ក្នុងកតិកាសសញ្ញាពិភពលោកនេះ។ ក្រសួងពាក់ព័ន្ធទាំងអស់មានការតាំងចិត្តក្នុងការចាត់វិធានការជាក់លាក់ដើម្បីអនុវត្ត GCM និងបានព្រាងផែនការអនុវត្តថ្នាក់ជាតិនេះឡើង តាមរយៈកិច្ចសហការដើម្បីឆ្លុះបញ្ចាំងពីគោលការណ៍ណែនាំរបស់ GCM ។ ផែនការអនុវត្តថ្នាក់ជាតិ គឺជាការប្រមូលផ្តុំធាតុចូលពីអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងអន្តរជាតិ បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍ និងសង្គមស៊ីវិល តាមរយៈការសហការរៀបចំសិក្ខាសាលាជាច្រើន ។ ក្នុងនាមជាអ្នកគាំទ្រ GCM តាំងពីការចាប់ផ្តើមដំបូង កម្ពុជាក៏ជាសមាជិក **'ជ័យលាភី'** នៃគំនិតផ្តួចផ្តើមនេះផងដែរ ហើយក៏ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន ៣០ ដំបូងគេ ដែលទទួលអនុវត្ត GCM និងមានឱកាស ផ្តល់នូវមេរៀនដែលទទួលបានការយល់ដឹងសំខាន់ៗ និងការអនុវត្តល្អៗសម្រាប់ប្រទេសផ្សេងៗទៀតអនុវត្តតាម។

## គោលបំណងជាអាទិភាព

នៅក្នុងឆ្នាំ ២០២០ និង ២០២១ តាមរយៈសិក្ខាសាលាអន្តរក្រសួងជាន់ខ្ពស់ជាបន្តបន្ទាប់ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសកម្មភាពអាទិភាពមួយចំនួន ដើម្បីឆ្លើយតបទៅនឹងគោលបំណងចំនួនបីដែលខ្លួនជឿជាក់ថានឹងអាចសម្រេចបានក្នុងរយៈពេលពេលពីរឆ្នាំដំបូងនៃការអនុវត្ត។ ការជ្រើសរើសទាំងនេះត្រូវបានធ្វើឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីឆ្លុះបញ្ចាំងពីកង្វល់ចម្បងៗរបស់ក្រសួង និងអ្នកពាក់ព័ន្ធនានា ដោយមានការអនុម័តពីនាយករដ្ឋមន្ត្រី។ ក្នុងការបង្កើតផែនការជាតិសម្រាប់អនុវត្តរយៈពេលពីរឆ្នាំនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការពិនិត្យ និងវាយតម្លៃលើសមិទ្ធផល និងគោលដៅរបស់ខ្លួននៅចុងបញ្ចប់នៃរយៈពេលពីរឆ្នាំនេះ។

ដោយមានការទទួលស្គាល់ពីតម្រូវការក្នុងការប្រមូលទិន្នន័យជាប្រព័ន្ធ និងដែលអាចជឿជាក់បានស្តីពីទេសន្តរប្រវេសន៍ សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង និងតម្រូវការក្នុងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធ្វើអោយប្រសើរឡើងនូវដំណើរការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍ រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសជាផ្លូវការនូវគោលបំណងអាទិភាពចំនួនបីសម្រាប់ការអនុវត្ត GCM។ គោលបំណងអាទិភាពទាំងបីរួមមាន៖ **<u>គោលបំណងទី១</u>** - ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមប្រភេទជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង ។ **<u>គោលបំណងទី ១១</u>** - គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា។ **<u>គោលបំណងទី ២៣</u>** - ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

**<u>គោលបំណងទី១</u>** មានអាទិភាពស្នូលចំនួនប្រាំ សម្រាប់ការអនុវត្តរយៈពេលពីរឆ្នាំដំបូង។ សកម្មភាពស្នូលសម្រាប់គោលបំណងនេះ គឺដើម្បីបង្កើតមូលដ្ឋានទិន្នន័យនៃរាល់ទិន្នន័យស្តីពីទេសន្តរប្រវេសន៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយរួមមួយ ដែលពេលបច្ចុប្បន្នមាននៅតាមក្រសួងនានានៃព្រះរាជាណាចក្រកម្ពុជា។ ជំហានបន្ទាប់មជ្ឈមណ្ឌលទិន្នន័យកណ្តាលអាចត្រូវបានប្រើដើម្បីបង្កើតរបាយការណ៍នៃទេសន្តរប្រវេសន៍នៅកម្ពុជា និងជាកិច្ចចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ពេលអនាគត ដើម្បីការកែលម្អវិធីសាស្ត្រ ការប្រមូល និងការប្រើប្រាស់ទិន្នន័យនៅក្នុងដំណាក់កាលអនុវត្តនាពេលអនាគត។ ស្របតាម GCM ការងារនេះនឹងត្រូវបានអនុវត្តដោយ "រក្សាសិទ្ធិឯកជនភាពក្រោមច្បាប់ស្តីសិទ្ធិមនុស្សអន្តរជាតិ និងការការពារទិន្នន័យផ្ទាល់ខ្លួន"។[1]

[1] *គោលបំណង GCM ១៖ "យើងប្តេជ្ញាពង្រឹងមូលដ្ឋានភស្តុតាងសកលស្តីពីទេសន្តរប្រវេសន៍អន្តរជាតិ តាមរយៈការកែលម្អ និងកិច្ចប្រឹងប្រែង ប្រមូល វិភាគ និងផ្សព្វផ្សាយទិន្នន័យដែលមានលក្ខណៈសុក្រិត ទុកចិត្តបាន ដោយបែងចែកតាមភេទ អាយុ ស្ថានភាពទេសន្តរប្រវេសន៍ និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធក្នុងបរិបទថ្នាក់ជាតិ ព្រមទាំងរក្សាបានសិទ្ធិឯកជនភាពក្រោមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងការការពារទិន្នន័យផ្ទាល់ខ្លួន។ ជាងនេះទៅទៀតយើងប្តេជ្ញាធានាឱ្យបានថាទិន្នន័យទាំងនេះនឹងជំរុញដល់ការស្រាវជ្រាវ និងត្រួសត្រាយសម្រាប់ការបង្កើតគោលនយោបាយផ្អែកលើភស្តុតាង និងមានលក្ខណៈស៊ីសង្វាក់ ដែលមានព័ត៌មានច្បាស់លាស់ ព្រមទាំងផ្តល់នូវ សេចក្តីប្រកាសសាធារណៈដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយ និង ទិន្នន័យដែលជួយក្នុងការតាមដាន និងវាយតម្លៃការអនុវត្តការសេចក្តីប្តេជ្ញាចិត្តប្រកបដោយប្រសិទ្ធភាព។"*

សកម្មភាពដែលត្រូវធ្វើឡើងក្រោមគោលបំណងទី ១១ ផ្តល់អាទិភាពលើការពង្រឹងកិច្ចសហប្រតិបត្តិការ និងនីតិវិធីគ្រប់គ្រងការឆ្លងកាត់ព្រំដែន ដោយផ្តោតជាសំខាន់លើព្រំដែនរវាងប្រទេសកម្ពុជា និងថៃ។ ដោយអនុលោមតាម GCM សកម្មភាពទាំងនេះនឹង "គោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ និងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ទាំងអស់ ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ហើយដោយមិនរើសអើង និង ឆ្លើយតបចំពោះចំណុចរសើបផ្នែកយេនឌ័រ និង កុមារ។"[2]

ជាចុងក្រោយ គោលបំណងទី ២៣ មានទិសដៅបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ ។ អាទិភាពស្នូលនៃគោលបំណងនេះគឺ ការពិនិត្យ និងវាយតម្លៃកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដែលមាន វាយតម្លៃការអនុវត្តនៃកិច្ចព្រមព្រៀងទាំងនោះ និងបង្កើតផែនការសកម្មភាពរួមគ្នាសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ដោយអនុលោមតាម GCM សកម្មភាពទាំងនេះនឹង "ជំរុញឱ្យមានការពង្រឹងគ្នាទៅវិញទៅមករវាងកតិកាសញ្ញាពិភពលោក និង ក្របខ័ណ្ឌច្បាប់អន្តរជាតិ និង គោលនយោបាយនានាដែលមានស្រាប់"។[3]

[2] *គោលបំណង GCM ១១៖ "យើងប្តេជ្ញាគ្រប់គ្រងព្រំដែនជាតិឱ្យមានលក្ខណៈស៊ីសង្វាក់ លើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគី និងថ្នាក់តំបន់ ធានាបានសន្តិសុខសម្រាប់ ប្រទេស សហគមន៍ និងជនទេសន្តរប្រវេសន៍ ព្រមទាំងសម្របសម្រួលសកម្មភាពឆ្លងកាត់ព្រំដែនប្រកបដោយសុវត្ថិភាព និងស្របច្បាប់ ដោយក្នុងពេលជាមួយគ្នាទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី។ យើងក៏ប្តេជ្ញាអនុវត្តគោលនយោបាយគ្រប់គ្រងព្រំដែនដែលគោរពអធិបតេយ្យភាពជាតិ នីតិរដ្ឋ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ និងសិទ្ធិរបស់ជនទេសន្តរប្រវេសន៍ទាំងអស់ ដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍របស់ពួកគេ ហើយដោយមិនមានការរើសអើង និង ឆ្លើយតបចំពោះចំណុចរសើបផ្នែកយេនឌ័រ និងកុមារ។"*

[3] *គោលបំណង GCM ២៣៖ "យើងប្តេជ្ញាគាំទ្រគ្នាទៅវិញទៅមកដោយយល់ដឹងពីគោលបំណង និងការតាំងចិត្តដែលមាននៅក្នុងកតិកាសញ្ញាពិភពលោកនេះ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ភាពជាដៃគូសកលក្នុងស្មារតីសាមគ្គីភាព ព្រមទាំងបញ្ជាក់បន្ថែមពីសារៈសំខាន់នៃវិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្សារភ្ជាប់គ្នា ដើម្បីសម្រួលដល់ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ និងទទួលស្គាល់ថាយើងទាំងអស់គ្នាជាប្រទេសដើម ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ។ យើងប្តេជ្ញាចាត់វិធានការរួមគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ប្រទេសនីមួយៗ ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោកនេះ គូសបញ្ជាក់ពីបញ្ហាប្រឈមជាក់លាក់ដែលជួបប្រទះ ជាពិសេសប្រទេសអាហ្វ្រិក បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសកំពុងអភិវឌ្ឍន៍គ្មានព្រំដែនជាប់សមុទ្រ រដ្ឋនៃកោះតូចៗកំពុងអភិវឌ្ឍ និងប្រទេសមានប្រាក់ចំណូលមធ្យម។ យើងក៏ប្តេជ្ញាលើកកម្ពស់ការពង្រឹងគ្នាទៅវិញទៅមករវាងកតិកាសញ្ញាពិភពលោក និង ក្របខ័ណ្ឌច្បាប់អន្តរជាតិ និង គោលនយោបាយនានាដែលមានស្រាប់ តាមរយៈការអនុវត្តកតិកាសញ្ញាពិភពលោកនេះឱ្យស៊ីសង្វាក់គ្នាជាមួយនឹងក្របខ័ណ្ឌផ្សេងៗ ជាពិសេសរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងរបៀបវារៈសកម្មភាព Addis Ababa និង ការទទួលស្គាល់ថាការធ្វើទេសន្តរប្រវេសន៍ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺមានលក្ខណៈពហុផ្នែក និងអាស្រ័យគ្នាទៅវិញទៅមក។"*

## ការអនុវត្ត ការពិនិត្យ និងការរាយការណ៍

ផែនការជាតិអនុវត្ត GCM នឹងត្រូវអនុម័តឱ្យប្រើសម្រាប់រយៈពេលពីរឆ្នាំ (២០២៣-២០២៥) ហើយផែនការសកម្មភាពក៏នឹងត្រូវបានបង្កើតឡើង បន្ទាប់ពីទទួលបានការអនុម័តជាផ្លូវការនៃផែនការជាតិអនុវត្ត GCM ។ ផែនការសកម្មភាពគឺជាផែនការលម្អិតបន្ថែមលើផែនការជាតិសម្រាប់អនុវត្ត GCM ដែលមានព័ត៌មានលម្អិតស្តីពីគម្រោងថវិកា និងអនុសកម្មភាពនានាដែលត្រូវបំបែកទៅតាមក្រសួងពាក់ព័ន្ធ ។ ការអនុវត្តផែនការសកម្មភាពចាំបាច់ត្រូវឆ្លើយតបនឹងយេនឌ័រ ព្រមទាំងផ្អែកលើសិទ្ធិមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជានឹងដឹកនាំការអនុវត្តផែនការសកម្មភាពទាំងនេះ ដោយមានការគាំទ្រពីសំណាក់ អង្គការតំណាងឱ្យកម្មករ អង្គការតំណាងនិយោជក សង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ។ ពលករទេសន្តរប្រវេសន៍ ស្ត្រី និងយុវជននឹងចូលរួមក្នុងការអនុវត្តផែនការសកម្មភាព និងការវាយតំលៃនៅគ្រប់ដំណាក់កាលដែលអាចធ្វើបាន។

រដ្ឋាភិបាល និងអង្គការដែលអនុវត្តផែនការសកម្មភាព ចាំបាច់ត្រូវជួបប្រជុំគ្នាជាទៀងទាត់ (ដោយធ្វើការកំណត់ក្នុងផែនការសកម្មភាព) ក្នុងកំឡុងពេលនៃការអនុវត្ត ដើម្បីចែករំលែកពីវឌ្ឍនភាព ដោះស្រាយបញ្ហាប្រឈម និងធានាបានថាការអនុវត្តមានដំណើរការទៅមុខ។

នៅចុងបញ្ចប់នៃរយៈពេលពីរឆ្នាំនេះ គួរតែមានការកំនត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃ ស្របតាមការវាយតំលៃថ្នាក់តំបន់ និងកាលបរិច្ឆេទរបស់ IMRF។ ដើម្បីជំរុញការវាយតម្លៃ និងកិច្ចប្រជុំត្រួតពិនិត្យតាមដំណាក់កាលនៃការអនុវត្តផែនការ និងដំណើរការ រាជរដ្ឋាភិបាលកម្ពុជាបានចាត់តាំងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ ដែលដឹកនាំដោយ លោកជំទាវ ជូ ប៊ុនអេង ដើម្បីទទួលខុសត្រូវដឹកនាំការងារនេះ។ ការវាយតំលៃ និងកិច្ចប្រជុំសត្រួតពិនិត្យត្រូវធ្វើឡើងដោយបង្កើនបរិយាកាសចូលរួម និងមានជាតុចូលពី សហជីព វិស័យឯកជន សង្គមស៊ីវិល និងអង្គការសហប្រជាជាតិ។

ប្រសិនបើអាចធ្វើទៅបាន និងមានការផ្តល់យោបល់តាមរយៈការវាយតំលៃ និងកិច្ចប្រជុំត្រួតពិនិត្យគោលបំណងមួយចំនួនទៀតគួរត្រូវបានបន្ថែម ដោយមានកំនត់នូវសកម្មភាពច្បាស់លាស់ សម្រាប់គោលដៅដែលបានបន្ថែមនីមួយៗ។

## សន្និដ្ឋាន

ជាចុងក្រោយ ការអនុម័តផែនការអនុវត្តជាតិសម្រាប់ GCM ជាការបញ្ជាក់បន្ថែមលើការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីភាពជាប់ពាក់ព័ន្ធនៃបញ្ហាទាក់ទងនឹងការធ្វើទេសន្តរប្រវេសន៍ និងបង្ហាញជាថ្មីម្តងទៀតពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការធ្វើការឆ្ពោះទៅកាន់វិធីសាស្ត្ររួមមួយសម្រាប់ទេសន្តរប្រវេសន៍។

| ផែនការអនុវត្តជាតិរយៈពេលពីរឆ្នាំ (ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២៣ -ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤) | | | | | |
|---|---|---|---|---|---|
| សកម្មភាពដែលស្នើដោយ GCM | វិធានការសម្រាប់អនុវត្ត | សូចនាករសំខាន់ៗ | ក្រសួង/អគ្គនាយកដ្ឋានទទួលបន្ទុក | ក្រសួង/នាយកដ្ឋានពាក់ព័ន្ធ | ពេលវេលា |
| គោលបំណងអាទិភាព | | | | | |
| គោលបំណងទី១៖ ប្រមូល និងប្រើប្រាស់ទិន្នន័យដែលអាចជឿជាក់បាន និងមានការបែងចែកតាមប្រភេទជាមូលដ្ឋាន | | | | | |
| អាទិភាពទី១៖ ពង្រឹងកិច្ចសហការរវាងក្រសួងនានា និងប្រទេសផ្តល់ទិន្នន័យ ដែលទទួលខុសត្រូវកត់ត្រាទិន្នន័យខុសៗគ្នាស្តីពី ទេសន្តរប្រវេសន៍ដើម្បីបង្កើតទិន្ន ន័យស្ថិតិស្តីពីទេសន្តរប្រវេសន៍រួមមួយ។<br><br>ឧបករណ៍៖ ៨. កំណត់ត្រាព្រំដែន កំណត់ត្រាទិដ្ឋាការ ប័ណ្ណស្នាក់នៅ កំណត់ត្រារដ្ឋបាល DOE ទិន្នន័យជំរឿន ការស្រាវជ្រាវស្ថិតិកម្លាំងពលកម្ម ការស្រាវជ្រាវសេដ្ឋកិច្ចសង្គម ទិន្នន័យឃុំសង្កាត់ | សកម្មភាព១.១៖បង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលកិច្ចសហការថ្នាក់ក្រសួង។<br><br>សកម្មភាព១.២៖ បង្កើតផែនទីទិន្នន័យនៃរាល់ទិន្ន ន័យទេសន្តរប្រវេសន៍ដែលមាននៅគ្រប់ក្រសួង និងអ្នកពាក់ព័ន្ធនានា ហើយកំនត់ថាតើមានការការពារឯកជនភាពអ្វីខ្លះ<br><br>សកម្មភាព ១.៣៖ បង្កើតនីតិវិធីប្រតិបត្តិស្តង់ដាស្តីពី ការចែករំលែកទិន្នន័យរវាងក្រសួង ដើម្បីបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យរួម | ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើង ហើយដំណើរការពិគ្រោះយោបល់លើកដំបូងត្រូវបានបញ្ចប់ ដែលជាលទ្ធផលបង្កើតបានជាយន្តការសហប្រតិបត្តិការរវាងក្រសួង។<br><br>ជំរឿនថ្នាក់ជាតិ មូលដ្ឋានទិន្នន័យឃុំ/សង្កាត់ ជំរឿនជាតិពាក់កណ្តាលអាណត្តិ ទិន្នន័យពីក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ ទិន្នន័យ | គ.ជ.ប.ជ និងក្រសួងព័ត៌មាន | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងផែនការ<br>អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | ឆមាសទី១ ឆ្នាំទី១ |

| | | | | | |
|---|---|---|---|---|---|
| | | ពីស្ថានទូត ទិន្នន័យពីក្រសួងសង្គមកិច្ចអតិតយុទ្ធជន និងយុវៈនីតិសម្បទា...។ល។ ត្រូវបានកំនត់ក្នុងផែនទីទិន្នន័យ និងជាលទ្ធផលនីតិវិធីប្រតិបត្តិស្តង់ដា ដែលទទួលស្គាល់ពីចន្លោះប្រហោងទិន្នន័យ ត្រូវបានអនុម័ត។ | | អគ្គស្នងការដ្ឋាននគរបាលជាតិ<br>នាយកដ្ឋានប្រឆាំងភេរវកម្ម និង ឧក្រិដ្ឋកម្មឆ្លងដែន<br>នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន<br>បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសន្តរប្រវេសន៍<br>អង្គការក្រៅរដ្ឋាភិបាល | |
| អាទិភាពទី២៖ មូលដ្ឋានទិន្នន័យរួម និងមានប្រសិទ្ធិភាពសម្រាប់ វិភាគ ផ្សព្វផ្សាយ និងចែករំលែក ដោះស្រាយទិន្នន័យដែលមានចន្លោះប្រហោង និងវាយតម្លៃលើនិន្នាការទេសន្តរប្រវេសន៍សំខាន់ៗដែលជំរុញឱ្យមានកិច្ចសហការរវាងភាគីពាក់ព័ន្ធនៅគ្រប់កម្រិត។ | សកម្មភាព ២.១៖ បង្កើតមូលដ្ឋានទិន្នន័យ/មជ្ឈមណ្ឌលទិន្នន័យ/វេទិកា (Platform) នៃទិន្នន័យ ស្តីពីទេសន្តរប្រវេសន៍ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយការពារទិន្នន័យផ្ទាល់ខ្លួន។<br><br>សកម្មភាព២.២៖ បញ្ចូលទិន្នន័យដែលមានទាំងអស់ទៅក្នុងវេទិកា(Platform) | ទិន្នន័យដែលគ្រប់គ្រងនៅថ្នាក់មជ្ឈិមមានភាពស៊ីសង្វាក់គ្នាពីគ្រប់ប្រភពទាំងអស់ និងត្រូវបានគ្រប់គ្រងនៅថ្នាក់អន្តរក្រសួង | ក្រសួងព័ត៌មាន | (ដូចខាងលើ) | ឆ្នាំទី១<br><br>ដំណើរការបន្ត |

| | | | | | |
|---|---|---|---|---|---|
| | ទិន្នន័យមូលដ្ឋាន ហើយសម្ភោតឱ្យប្រើជាផ្លូវការ។ | | | | |
| អាទិភាពទី៣៖ បង្កើតរបាយការណ៍ស្តីពីទេសន្តរប្រវេសន៍កម្ពុជាដែលរួមមាន៖ ទិន្នន័យបែងចែកតាមប្រភេទជាមូលដ្ឋាន និន្នាការទីផ្សារការងារ ឥទ្ធិពលនៃទេសន្តរប្រវេសន៍ លើផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម ការចំណាយលើការផ្ទេរប្រាក់ មកផ្ទះ សុខភាព ការអប់រំ មុខរបរ ការរស់នៅ និងលក្ខខណ្ឌការងារ ប្រាក់ឈ្នួល និងតម្រូវការរបស់ជនទេសន្តរប្រវេសន៍ ដើម្បីបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ផ្អែកលើភស្តុតាង | សកម្មភាព៣.១៖ កសាងនិងលើកកំពស់សមត្ថភាពរបស់ក្រសួងពាក់ព័ន្ធក្នុងការប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យ។<br><br>សកម្មភាព៣.២៖ បង្កើតរបាយការណ៍ស្តីពីទេសន្តរប្រវេសន៍នៅកម្ពុជាផ្អែកលើចំណេះដឹងទិន្នន័យដែលបានធ្វើឱ្យប្រសើរឡើង។ | ភាគីពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងការបង្កើត ការវិភាគ និងការបង្រួបបង្រួមទិន្នន័យ<br><br>របាយការណ៍ស្តីពីទេសន្តរប្រវេសន៍ត្រូវបានបញ្ចប់ដោយមានធាតុចូលជាយុទ្ធសាស្ត្រពីភាគីពាក់ព័ន្ធខាងរដ្ឋាភិបាល និងសង្គមស៊ីវិល | គ.ជ.ប.ជ និងក្រសួងព័ត៌មាន | (ដូចខាងលើ) | ឆ្នាំទី២ |
| អាទិភាពទី៤៖ យុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយសម្រាប់ធ្វើឱ្យទិន្នន័យទេសន្តរប្រវេសន៍កាន់តែប្រសើរឡើង តាមរយៈការ | សកម្មភាព ៤.១៖ បង្កើតយុទ្ធសាស្ត្រ និងដំណើរការបណ្តុះបណ្តាលសម្រាប់រដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ | ប្រភពទិន្នន័យ ភាពចន្លោះប្រហោង ស្តង់ដារ និងវិធីសាស្ត្រត្រូវបានពិនិត្យ និងវាយតម្លៃជាប្រព័ន្ធ ដោយ | ក្រសួងព័ត៌មាន<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងព័ត៌មាន<br>ក្រសួងផែនការ | ឆមាសទី២ ឆ្នាំទី២ |

| | | | | | |
|---|---|---|---|---|---|
| ចូលរួមពីស្ថាប័នពាក់ព័ន្ធ និងធ្វើឱ្យវិធីសាស្ត្រប្រមូលទិន្នន័យប្រកបដោយភាពរលូន និងពង្រឹងការវិភាគ និងការផ្សព្វផ្សាយទិន្នន័យ និងសូចនាករទាក់ទងនឹងការធ្វើទេសន្តរប្រវេសន៍។ | អន្តរជាតិសំខាន់ៗ ដើម្បីកែលម្អគុណភាពទិន្នន័យ។<br><br>៤.២៖ ពង្រឹងប្រភពទិន្នន័យ ដើម្បីបង្កើនគុណភាពទិន្នន័យថ្នាក់ជាតិស្តីពីទេសន្តរប្រវេសន៍ការងារ។<br><br>៤.៣៖ ពង្រឹង និងកែលម្អការបញ្ជូនទិន្នន័យទេសន្តរប្រវេសន៍ការងារកម្ពុជាប្រចាំឆ្នាំទៅកាន់មូលដ្ឋានស្ថិតិទេសន្តរប្រវេសន៍ការងារអន្តរជាតិ (ILMS) | មានធាតុចូល និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់<br><br>គោលបំណងសម្រាប់ការកែលម្អទិន្នន័យត្រូវបានព្រាងសម្រាប់ដាក់បញ្ចូលក្នុងផែនការជាតិសម្រាប់អនុវត្ត GCM បន្ទាប់<br><br>ស្ថិតិការងារកម្ពុជាត្រូវបានកែលម្អ និងមាននៅក្នុង ILMS | | បណ្តាញអង្គការសហប្រជាជាតិស្តីពីទេសសន្តរប្រវេសន៍ | |
| អាទិភាពទី៥៖ ការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យឱ្យបានទៀងទាត់ស្តីពីផលប៉ះពាល់ និងអត្ថប្រយោជន៍នៃការធ្វើទេសន្តរប្រវេសន៍ដែលអាចប្រើសម្រាប់ជាព័ត៌មានក្នុងការអនុវត្តរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ | សកម្មភាព៥.១៖ ធ្វើការពិនិត្យឡើងវិញដោយមានការរួមបញ្ចូលភាគីពាក់ព័ន្ធទាំងអស់ ដើម្បីវាយតម្លៃការអនុវត្ត GCM នៅក្នុងបរិបទនៃរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព<br><br>សកម្មភាព៥.២៖ កែសម្រួលផែនការសកម្មភាពជាតិដែលពាក់ព័ន្ធដើម្បីដាក់បញ្ចូលគោលបំណងរបស់ GCM | GCM ត្រូវបានវាយតម្លៃដោយភ្ជាប់ជាមួយនឹងការវាយតម្លៃ SDG តាមតាមដំណាក់កាល<br><br>គោលបំណងរបស់ GCM ត្រូវបានសម្រួលបញ្ចូលទៅក្នុងរបៀបវារៈជាតិ SDG ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និង | ក្រសួងផែនការ | | ឆមាសទី២ ឆ្នាំទី១ |

| | | | | | |
|---|---|---|---|---|---|
| | | ការពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត | | | |
| គោលបំណងទី ១១៖ គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីសង្វាក់គ្នា | | | | | |
| អាទិភាពទី៦៖ ការពង្រឹងកិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែន (ឧ. ការកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ ការបញ្ជូនបន្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ការផ្តល់ជំនួយ និងកិច្ចការពារសមស្របសម្រាប់ជនទេសន្តរប្រវេសន៍ក្នុងស្ថានភាពងាយរងគ្រោះ)។ | សកម្មភាព៦.១៖ បង្កើត/បន្តសុពលភាព/ធានាឱ្យមានជនបង្គោលសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនជាមួយប្រទេសថៃ ម៉ាឡេស៊ី និង ចិន។<br><br>សកម្មភាព៦.២៖ ធ្វើការពិនិត្យ ដោយមានការចូលរួមពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ដើម្បីធានាថានីតិវិធីឆ្លងកាត់ព្រំដែនស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ | កិច្ចសហប្រតិបត្តិការឆ្លងព្រំដែនជាមួយប្រទេសជិតខាងត្រូវបានសម្រួលតាមរយៈការទំនាក់ទំនង និងការចែករំលែកព័ត៌មានជាប្រចាំ។<br><br>នីតិវិធីឆ្លងកាត់ព្រំដែនបច្ចុប្បន្នត្រូវបានវាយតម្លៃ ហើយជាលទ្ធផលផែនការសកម្មភាពដើម្បីកែលម្អការអនុវត្តត្រូវបានរៀបចំឡើង។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការពារជាតិ (នាយកដ្ឋានកណ្តាលនគរបាលព្រំដែន) | អង្គភាពប្រដាប់អាវុធទាំង៦៖ អគ្គស្នងការនគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ការិយាល័យព្រំដែន (ក្រសួងការពារជាតិ)។ | ឆ្នាំទី១ |
| អាទិភាពទី៧៖ ការធានាឱ្យមានរចនាសម្ព័ន្ធ និងយន្តការសមស្របសម្រាប់ការគ្រប់គ្រងព្រំដែនប្រកបដោយប្រសិទ្ធភាពតាមរយៈនីតិវិធី | សកម្មភាព៧.១៖ ធ្វើធ្វើការវាយតម្លៃលើការគ្រប់គ្រងព្រំដែនឆ្ពោះទៅរកនីតិវិធី (ឧ. ការពិនិត្យអ្នកដំណើរ របាយការណ៍ពីក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងការ | នីតិវិធីព្រំដែនបច្ចុប្បន្នត្រូវបានវាយតម្លៃ និងកែលម្អក្នុងបរិបទនៃការគោរពសិទ្ធិ និងកិច្ចការពារជនងាយរង | ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ (នាយកដ្ឋានកណ្តាល | អង្គភាពប្រដាប់អាវុធទាំង៦រួមមាន៖អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេ | ឆ្នាំទី២ |

| | | | | | |
|---|---|---|---|---|---|
| ឆ្លងកាត់ព្រំដែនដែលប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ | ប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន) គោរពគោលការណ៍គ្មានការរើសអើង ការគោរពសិទ្ធិឯកជនភាព និងការការពារទិន្នន័យផ្ទាល់ខ្លួន។<br><br>សកម្មភាព៧.២៖ បង្កើត និងអនុវត្តប្រព័ន្ធកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលអន្តោប្រវេសន៍ និងប៉ូលីសព្រំដែនជួរមុខ ស្របតាម GCM | គ្រោះ ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងកិច្ចព្រមព្រៀង និងឧបករណ៍អន្តរជាតិ។<br><br>សមត្ថភាពមន្ត្រីព្រំដែន ដើម្បីអនុវត្តនិតិវិធីគ្រប់គ្រងព្រំដែនប្រកបដោយប្រសិទ្ធភាពត្រូវបានពង្រឹង។ | នគរបាលព្រំដែន) | សន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ទីចាត់ការព្រំដែន(ក្រសួងការពារជាតិ) | |
| អាទិភាពទី៨៖ អាជ្ញាធរមានសមត្ថកិច្ចការពារកុមារត្រូវបានជូនដំណឹងភ្លាមៗ និងចាត់តាំងឱ្យចូលរួមក្នុងនីតិវិធីសម្រាប់កុមារដែលពុំមានអ្នករួមដំណើរជាមួយ ឬកុមារធ្វើទេសន្តរប្រវេសន៍ ចូល/ចេញពីប្រទេសកម្ពុជាម្នាក់ឯង។ | សកម្មភាព៨.១៖ វាយតម្លៃគោលនយោបាយព្រំដែន និងកែសម្រួល SOP ដើម្បីធានាថាយន្តការការពារកុមារត្រូវបានរួមបញ្ចូលនៅកម្រិតនីមួយៗនៃការគ្រប់គ្រងព្រំដែន។ | សមត្ថភាពមន្ត្រីព្រំដែនក្នុងការកំណត់អត្តសញ្ញាណ និងការពារកុមារដែលពុំមានអ្នករួមដំណើរ ឬកុមារធ្វើដំណើរម្នាក់ឯងត្រូវបានធ្វើឱ្យប្រសើរឡើង។ | ក្រសួងការពារជាតិ (នាយកដ្ឋានកណ្តាលនគរបាលព្រំដែន) | អង្គភាពប្រដាប់អាវុធទាំង៦រួមមាន៖អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ទីចាត់ការព្រំដែន(ក្រសួងការពារជាតិ) | ឆ្នាំទី២ |
| គោលបំណងទី ២៣៖ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ | | | | | |

| | | | | | |
|---|---|---|---|---|---|
| អាទិភាពទី៩៖ បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបង្កើនឱកាសក្នុងការទទួលបានលការធ្វើទេសន្តរប្រវេសន៍ប្រក្រតី។ | សកម្មភាព៩.១៖ ពិនិត្យជាលក្ខណៈប្រព័ន្ធ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ កិច្ចព្រមព្រៀង និងយន្តការ ក្នុងគោលបំណងពង្រឹងមាគ៌ាទេសន្តរប្រវេសន៍ស្របច្បាប់ ហើយអនុលោមតាមច្បាប់អន្តរជាតិ។<br><br>សកម្មភាព៩.២៖ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសហជីព វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ធ្វើការវាយតម្លៃស៊ីជម្រៅលើលទ្ធភាពទទួលបានការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍មិនប្រក្រតី។ | កិច្ចព្រមព្រៀង MOUs និង SOPs ដែលមានស្រាប់ ត្រូវបានពិនិត្យឡើងវិញតាមរយៈដំ ណើរការអន្តរក្រសួង។ ក្នុងបរិបទនៃព្រឹត្តិ ការណ៍បច្ចុប្បន្ន រួមទាំងមេរោគ COVID-19 បានបណ្តាលឱ្យមានផែនការសកម្មភាពដើម្បីពង្រឹងការអនុវត្ត និងការលើកកម្ពស់ការយល់ដឹងអំពីយុទ្ធសាស្ត្រយុទ្ធនាការជាតិ។ | ក្រសួងមហាផ្ទៃ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងសុខាភិបាល<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>អង្គការសហប្រជាជាតិ<br>អង្គការក្រៅរដ្ឋាភិបាល | ឆមាសទី១ ឆ្នាំទី១ |
| អាទិភាពទី១០៖ ភាពជាដៃគូទ្វេភាគីថ្នាក់តំបន់ ឬពហុភាគី និងកិច្ចព្រមព្រៀងកំណត់ទិសដៅដំណោះស្រាយនៃចំពោះគោលនយោបាយទេសន្តរប្រវេសន៍ និងដោះស្រាយឱកាស និងបញ្ហាប្រឈមនៃទេសន្តរ | សកម្មភាព១០.១៖ រៀបចំការពិនិត្យថ្នាក់អន្តរក្រសួងដែលមានការចូលរួមពីសហជីព វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដែលមាន | ការអនុវត្តកិច្ចព្រមព្រៀងដែលមានស្រាប់ MOUs និង SOPs ត្រូវបានពង្រឹងតាមរយៈការធ្វើឱ្យប្រសើរឡើងនូវពិភាក្សាពហុភាគី ជាមួយប្រទេសពាក់ព័ន្ធ។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងការបរទេស និង | ក្រសួងកិច្ចការនារី<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>អជ្ញាធរថ្នាក់ក្រោមជាតិ<br>ក្រសួងសុខាភិបាល | ឆ្នាំទី២ |

| | | | | | |
|---|---|---|---|---|---|
| ប្រវេសន៍ ដោយអនុលោមតាមកតិកាសញ្ញាពិភពលោក។ | ស្រាប់ទាំងអស់ (ឧ. COMMIT, MOUs ជាមួយ ប្រទេសថៃ ម៉ាឡេស៊ី ចិន)<br><br>សកម្មភាព១០.២៖ បង្កើតផែនការសកម្មភាព/ផែនការការងាររួមគ្នាជាមួយស្ថាប័នអន្តរជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព។<br><br>សកម្មភាព១០.៣៖ រៀបចំការពិនិត្យថ្នាក់អន្តរក្រសួងដែលមានការចូលរួមពីសង្គមស៊ីវិល សហជីព និងសង្គមស៊ីវិល (រួមបញ្ចូលភ្នាក់ងារជ្រើសរើសពលករ) និង អ្នកពាក់ព័ន្ធអន្តរជាតិសំខាន់ៗ ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់ភ្នាក់ងារជ្រើសរើសពលករចំពោះជនទេសន្តរប្រវេសន៍។<br><br>សកម្មភាព១០.៤៖ បង្កើតផែនការសកម្មភាពរួមគ្នាជាមួយប្រទេសថៃ ដើម្បី | ការកេងប្រវ័ញ្ចលើពលករទេសន្តរប្រវេសន៍នៅកម្រិតជ្រើសរើសត្រូវបានពិនិត្យ និងកាត់បន្ថយ តាមរយៈដំណើរការបណ្តុះបណ្តាលសម្រាប់ពលករប្រសើរជាងមុន និងអត្រាការយល់ដឹងពីការកេងប្រវ័ញ្ចខ្ពស់។ | សហប្រតិបត្តិការអន្តរជាតិ | ទីភ្នាក់ងារជ្រើសរើសពលករ<br>អង្គការសហប្រជាជាតិ<br>អង្គការក្រៅរដ្ឋាភិបាល<br>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | |

| | | | | | |
|---|---|---|---|---|---|
| | តាមដាន និងវាយតម្លៃ យុទ្ធសាស្ត្រជ្រើសរើស ពលកររបស់ផ្នែកឯកជន។ | | | | |
| អាទិភាពទី១១៖ អាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលចូលរួមនៅក្នុងការកំណត់នូវតម្រូវការ និងឱកាសសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអនុវត្តកតិកាសញ្ញាប្រកបដោយប្រសិទ្ធភាព។ | សកម្មភាព១១.១៖ សហការ និងចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធសង្គមស៊ីវិល ដើម្បីធ្វើសមាហរណកម្មទស្សនៈ និងអាទិភាពរបស់ពួកគេទៅក្នុងការធ្វើឱ្យស្របច្បាប់នៃការវិលត្រឡប់វិញរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា តាមរយៈការកែសម្រួលគោលនយោបាយ និងនីតិវិធីប្រតិបត្តិស្តង់ដា។ | វិធានការទប់ស្កាត់ និងកាត់បន្ថយអំពើពុករលួយពាក់ព័ន្ធនឹងការឆ្លងកាត់ព្រំដែនមិនប្រក្រតី ត្រូវបានណែនាំ និង/ឬពង្រឹងបន្ថែម | ក្រសួងមហាផ្ទៃ | | ឆមាសទី២ ឆ្នាំទី១ |
| អាទិភាពទី១២៖ កិច្ចការការពារសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ត្រូវបានពង្រីក និងលទ្ធភាពនៃការផ្ទេរអត្ថប្រយោជន៍សន្តិសុខសង្គមត្រូវបានលើកកំពស់ | សកម្មភាព ១២។១៖ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រទេសថៃ ស្តីពីនីតិវិធីនៃការវិលត្រឡប់មកវិញដោយសុវត្ថិភាពសម្រាប់ពលករទេសន្តរប្រវេសន៍ត្រលប់មកប្រទេសកម្ពុជា។<br><br>សកម្មភាព ១២.២៖ បង្កើត SOP ទ្វេភាគីជាមួយរដ្ឋាភិបាលថៃ ដើម្បីធានាថាការវិលត្រឡប់របស់ពលករទេសន្តរប្រវេសន៍ធ្វើឡើងប្រកប ដោយសុវត្ថិភាព។ | ការពិភាក្សាជាមួយប្រទេសគោលដៅសម្រាប់ការផ្ទេរអត្ថប្រយោជន៍ប្រកបដោយប្រសិទ្ធភាពត្រូវបានបង្កើតឡើង | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ដំណើរការបន្ត |

| | | | | | |
|---|---|---|---|---|---|
| | សកម្មភាព១២.៣៖ តាមរយៈធាតុចូលបានពីដំណើរការអនុវត្ត GCM ការចូលរួមក្នុង CLMT និង ASEAN សម្រាប់ការលើកកម្ពស់លទ្ធភាពនៃការផ្ទេរអត្ថប្រយោជន៍សន្តិសុខសង្គម។ | | | | |